SAN JOAQUIN COUNTY
BEHAVIORAL HEALTH SERVICES

1212 NORTH CALIFORNIA STREET
STOCKTON, CA 95202
(209) 468-8859

# សេចក្តីជូនដំណឹងអំពីការអនុវត្តន៍ផ្ទាល់ខ្លួន



## ពត៌មានរបស់អ្នក
## សិទ្ធិរបស់អ្នក
## ការទទួលខុសត្រូវរបស់អ្នក

ការប្រកាសនេះពិពណ៌នាអំពីរបៀបដែលពត៌មានសុខភាពរបស់អ្នក អាចត្រូវបានប្រើប្រាស់ និងបញ្ចេញ ព្រមទាំងរបៀបដែលអ្នកមានសិទ្ធិអាចប្រើប្រាស់ពត៌មាននេះ។ សូមពិនិត្យមើលឡើងវិញដោយយកចិត្តទុកដាក់។

## សិទ្ធិរបស់លោកអ្នក

**ពេលដែលចាប់ប្រើពត៌មានសុខភាពរបស់អ្នក, អ្នកមានសិទ្ធិដែលបានកំណត់មកហើយ។** ក្នុងផ្នែកនេះ ពន្យល់អំពីសិទ្ធិរបស់អ្នក និងការទទួលខុសត្រូវរបស់យើងខ្លះដើម្បីជួយដល់អ្នក

| | |
|---|---|
| **ទទួលបានសំណុំរឿងសុខភាពនិងការទាមទារមួយច្បាប់** | • អ្នកអាចសុំមើល ឬទទួលបានក្រដាសថតចម្លងសំណុំរឿងសុខភាព និងការទាមទាររបស់អ្នក និងពត៌មានសុខភាពដទៃទៀត ដែលយើងមានអំពីអ្នក។ សួរយើងពីបែបទទួលបាននេះ។<br>• យើងនឹងផ្តល់ក្រដាសថតចម្លង ឬសំណុំរឿងសង្ខេបនៃសុខភាព និងការទាមទាររបស់អ្នក។ ជាធម្មតាក្នុងរវាង៣០ថ្ងៃ ចាប់ពីការស្នើសុំរបស់អ្នក។ យើងអាចមានការផ្លាស់ប្តូរតម្លៃថោកដែលសមហេតុផល។ |
| **សុំយើងកែសំណុំរឿងសុខភាពនិងការទាមទារ** | • អ្នកអាចសុំយើងឲ្យកែសំណុំរឿងសុខភាព និងការទាមទាររបស់អ្នក បើអ្នកគិតថាវាមិនត្រឹមត្រូវ ឬមិនគ្រប់សព្វ។ សួរយើងពីបែបកែសំណុំរឿងនេះ។<br>• យើងអាចថា“ទេ”ក្នុងការស្នើសុំរបស់អ្នក, តែយើងនឹងប្រាប់អ្នកពីហេតុក្នុងក្រដាសស្នាមក្នុងរវាង៦០ថ្ងៃ។ |
| **ស្នើសុំផ្តល់ការទាក់ទងជាសម្ងាត់** | • អ្នកអាចសុំយើងឲ្យទាក់ទងមកអ្នកក្នុងរបៀបជាក់លាក់(ឧទាហរណ៍,ទូរស័ព្ទផ្ទះឬការិយាល័យ) ឬផ្ញើសំបុត្រមកអស័យដ្ឋានផ្សេងគ្នា<br>• យើងនឹងពិចារណាការស្នើសុំទាំងអស់ដែលសមហេតុផល នឹងត្រូវថា“បាទ/ចាស៎”បើអ្នកប្រាប់យើងថាអ្នកអាចមានគ្រោះថ្នាក់ បើយើងមិនផ្តល់ការទាក់ទងជាសម្ងាត់ទេ។ |

## សិទ្ធិរបស់លោកអ្នក (ត)

**សុំយើងឲ្យកំរិតអ្វីដែលយើងប្រើ ឬចែកចាយ**

- អ្នកអាចសុំយើងមិនឲ្យប្រើ ឬចែកចាយពត៌មានអ្វីមួយនៃសុខភាព សំរាប់ការព្យាបាល, ការបង់ថ្លៃ, ឬការប្រើប្រាស់របស់យើង។
- យើងមិនបានតម្រូវឲ្យយល់ព្រមតាមការស្នើសុំរបស់អ្នកទេ, ហើយយើងអាចថា"ទេ"បើវាមានឥទ្ធិពលសំរាប់ការថែរក្សាអ្នក។
- បើអ្នកបង់ថ្លៃពេញពីហោប៉ៅ សំរាប់ការព្យាបាល ឬការថែទាំសុខភាព, អ្នកអាចសុំយើងមិនឲ្យចែកចាយពត៌មាននោះ សំរាប់គោលបំណងនៃការបង់ថ្លៃ ឬការប្រើប្រាស់ជាមួយអ្នកធានារ៉ាប់រងសុខភាពរបស់អ្នក។
- យើងនឹងថា"បាទ/ចាស៎"លើកតែច្បាប់បានតម្រូវឲ្យយើងចែកចាយពត៌មាននោះ។

---

**ទទួលបានបញ្ជីនៃអស់អ្នកដែលយើងបានចែកចាយពត៌មានជាមួយគេ**

- អ្នកអាចសុំបញ្ជី(គណនេយ្យ)នៃពេលវេលា ដែលយើងបានចែកចាយពត៌មានសុខភាពរបស់អ្នក សំរាប់ប្រាំមួយឆ្នាំមុនទៅដល់ថ្ងៃខែដែលអ្នកសុំ, ពីអ្នកណាដែលយើងចែកចាយជាមួយនិងដោយហេតុអ្វី។
- យើងនឹងបន្ថែមអស់ទាំងការបញ្ចេញឲ្យគេដឹង លើកលែងតែសំរាប់ការព្យាបាលទាំងនោះ, ការបង់ថ្លៃ, និងការប្រើប្រាស់ថែរក្សាសុខភាព, និងការបញ្ចេញផ្សេងទៀតដែលបានកំណត់(ដូចជាណាមួយដែលអ្នកបានសុំយើងឲ្យធ្វើ)។ យើងនឹងផ្តល់គណនេយ្យមួយក្នុង១ឆ្នាំដោយឥតគិតថ្លៃ តែនឹងគិតថ្លៃថោកដែលសមហេតុផល បើអ្នកសុំមួយទៀតក្នុងរយៈពេល១២ខែ។

---

**ទទួលបានសេចក្តីជូនដំណឹងផ្ទាល់នេះ១ច្បាប់**

- អ្នកអាចសុំក្រដាសថតចម្លងនៃសេចក្តីជូនដំណឹងនេះគ្រប់ពេល សូម្បីតែអ្នកបានយល់ព្រមទទួលសេចក្តីប្រកាសនេះតាមអេឡិចត្រូនិច។ យើងនឹងផ្តល់ក្រដាសថតចម្លងឲ្យអ្នកយ៉ាងឆាប់។

---

**ដាក់ពាក្យបណ្តឹងបើអ្នកមានអារម្មណ៍ថាសិទ្ធិរបស់អ្នកត្រូវបានបំពាន**

- អ្នកអាចប្តឹងតវ៉ា បើអ្នកមានអារម្មណ៍ថាយើងបានបំពានលើសិទ្ធិរបស់អ្នក ដោយការទាក់ទងយើង ប្រើប្រាស់ពត៌មាននៅទំព័រទី១។
- អ្នកអាចដាក់ពាក្យបណ្តឹងជាមួយ the U.S. Department of Health and Human Services Office សំរាប់សិទ្ធិនៃជនស៊ីវិល ដោយផ្ញើសំបុត្រទៅ 200 Independence Avenue, S.W., Washington, D.C. 20201, ទូរស័ព្ទ 1-877-696-6775, ឬចូលទៅក្នុងអ៊ិនធ័រណែត www.hhs.gov/ocr/privacy/hipaa/complaints/
- យើងនឹងមិនតបស្នងចំពោះអ្នក សំរាប់ការដាក់ពាក្យបណ្តឹងទេ។

---

## ជំរើសរបស់លោកអ្នក

**សំរាប់ពត៌មានអ្វីមួយនៃសុខភាព, អ្នកអាចប្រាប់យើងពីជំរើសរបស់អ្នកអំពីអ្វីដែលយើងចែកចាយ។** បើអ្នកមានការចូលចិត្តច្បាស់ ពីបែបឲ្យយើងចែកចាយពត៌មានរបស់អ្នក ក្នុងកាលៈទេសៈដែលបានពិពណ៌នាខាងក្រោមនិយាយមកយើង។ ប្រាប់យើងពីអ្វីដែលអ្នកចង់ឲ្យយើងធ្វើ ហើយយើងនឹងធ្វើទៅតាមសេចក្តីណែនាំរបស់អ្នក។

---

**ក្នុងករណីយទាំងនេះ អ្នកមានទាំងសិទ្ធិ និងជំរើសដើម្បីប្រាប់យើងចំពោះ៖**

- ការចែកចាយពត៌មានជាមួយគ្រួសារអ្នក, មិត្តសម្លាញ់, ឬអ្នកឯទៀតដែលជាប់ទាក់ទងក្នុងការបង់ថ្លៃសំរាប់ការថែរក្សាអ្នក។
- ការចែកចាយពត៌មានសំរាប់ជួយក្នុងកាលៈទេសៈមហន្តរាយ។

បើអ្នកមិនអាចនឹងប្រាប់ដល់យើងអំពីចំណូលចិត្តរបស់អ្នក, ឧទាហរណ៍ បើអ្នកឥតដឹងខ្លួន, យើងអាចចែកចាយពត៌មានរបស់អ្នកបាន បើអ្នកជឿថាវាគឺផលប្រយោជន៍ល្អបំផុតសំរាប់អ្នក។ យើងអាចចែកចាយពត៌មានរបស់អ្នក ពេលដែលត្រូវការធ្វើឲ្យអន់ថយ ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ និងអាសន្នដែលនឹងកើតមានឡើងចំពោះសុខភាព ឬសុវត្ថិភាព។

## ការប្រើនិងការបញ្ចេញរបស់យើង

**តើបែបធម្មតាណា ដែលយើងប្រើឬចែកចាយពត៏មានសុខភាពរបស់អ្នក?** តាមបែបធម្មតាយើងប្រើឬចែកចាយពត៏មានសុខភាពរបស់អ្នកក្នុងបែបផ្សេងៗខាងក្រោម។

| | | |
|---|---|---|
| **ជួយគ្រប់គ្រងការថែរក្សាព្យាបាលសុខភាពអ្នកបានទទួល** | • យើងអាចប្រើពត៏មានសុខភាពរបស់អ្នក និងចែកចាយពត៏មានជាមួយអ្នកជំនាញការដែលកំពុងព្យាបាលអ្នក។ | ឧទាហរណ៍: វិជ្ជបណ្ឌិតផ្ញើពត៏មានមកយើងអំពីរោគវិនិច្ឆ័យ និងគំរោងការព្យាបាល ដូច្នេះយើងអាចសំរួលបន្ថែមលើការព្យាបាល |
| **ការកាន់កាប់ចាត់ចែងរបស់យើង** | • យើងអាចប្រើ និងបញ្ចេញពត៏មានរបស់អ្នកសំរាប់ការកាន់កាប់ចាត់ចែងរបស់យើង និងទាក់ទងមកអ្នក ពេលដែលចាំបាច់។ | ឧទាហរណ៍: យើងប្រើពត៏មានសុខភាពអំពីអ្នក ដើម្បីបង្កើតការព្យាបាលប្រសើរជាងសំរាប់អ្នក។ |
| **សំបុត្រគិតលុយសំរាប់ការព្យាបាលរបស់អ្នក** | • យើងអាចប្រើនិងចែកចាយពត៏មានរបស់អ្នកដើម្បីគិតលុយនិងទទួលការបង់ថ្លៃអំពីគំរោងព្យាបាលសុខភាពនិងអង្គភាពឯទៀត | ឧទាហរណ៍: យើងប្រើពត៏មានសុខភាពអំពីអ្នក ដើម្បីបង្កើតការព្យាបាលប្រសើរជាងសំរាប់អ្នក។ |

**តើបែបផ្សេងទៀតណា ដែលយើងប្រើឬចែកចាយពត៏មានសុខភាពរបស់អ្នក?** យើងបានអនុញ្ញាតិ ឬបានតម្រូវឲ្យចែកចាយពត៏មានរបស់អ្នកក្នុងបែបឯទៀត-ជាធម្មតាក្នុងបែបដែលជួយផ្តល់ការល្អដល់សាធារណៈ,ដូចជាក្រសួងសុខភាពសាធារណៈ និងការស្រាវជ្រាវ។ យើងធ្វើតាមលក្ខខ័ណ្ឌក្នុងច្បាប់ មុនពេលយើងអាចចែកចាយពត៏មានរបស់អ្នក សំរាប់គោលបំណងទាំងអស់នេះ។ សំរាប់ពត៏មានជាច្រើនទៀតសូមមើល :

**www.hhs.gov/ocr/privacy/hipaa/understanding/consumers/index.html**

| | |
|---|---|
| ប្រតិបត្តិតាមច្បាប់ | • យើងនឹងចែកចាយពត៏មានអំពីអ្នក បើច្បាប់នៃរដ្ឋឬសហព័ន្ធតម្រូវឲ្យ, រួមជាមួយ the Department of Health and Human Services បើគេចង់មើល នោះយើងប្រតិបត្តិតាមច្បាប់ឯកជន(ផ្ទាល់ខ្លួន)នៃសហព័ន្ធ។ |
| ធ្វើការជាមួយពេទ្យត្រួតពិនិត្យ ឬនាយកខាងការបញ្ចុះឬបូជាសព | • យើងអាចចែកចាយពត៏មានអំពីអ្នក ជាមួយអ្នកធ្វើវិភាគសព,ពេទ្យត្រួតពិនិត្យមើល, ឬនាយកខាងការបញ្ចុះឬបូជាសព នៅពេលមានអ្នកណាម្នាក់ស្លាប់។ |
| ឆ្លើយតបចំពោះរឿងក្តីនិងបណ្តឹងតាមច្បាប់ | • យើងអាចចែកចាយពត៏មានអំពីអ្នក ក្នុងការឆ្លើយតបទៅតុលាការ ឬការបញ្ជាពីទីចាត់ការ ឬតបឆ្លើយចំពោះដីកាកោះហៅ។ |
| ដំណើរការឈោងទៅក្រៅការចុះឈ្មោះ,សំរបសំរួលការថែរក្សា និងការកាន់កាប់សំណុំរឿង | • យើងអាចចែកចាយពត៏មានរបស់អ្នក ជាមួយកម្មវិធីទទួលប្រយោជន៍ពីរដ្ឋាភិបាលឯទៀត ដូចជា Covered California សំរាប់មូលហេតុដូចជាការឈោងទៅខាងក្រៅ, ការចុះឈ្មោះ, សំរបសំរួលការថែរក្សា, និងការកាន់កាប់សំណុំរឿង។ |
| ប្រតិបត្តិតាមច្បាប់ពិសេស | • មានច្បាប់ពិសេសដែលការពារបែបនៃពត៏មានសុខភាពខ្វះ ដូចជាការព្យាបាលវិបត្តិផ្លូវចិត្ត, ព្យាបាលសំរាប់ការប្រើសារធាតុដែលឥតមានរបៀបរៀបរយ និងការពិសោធ និងការព្យាបាល HIV/AIDS ។ យើងនឹងធ្វើតាមច្បាប់ទាំងអស់នេះ ពេលគេតឹងរ៉ឹងជាងសេចក្តីប្រកាសនេះ។ |

យើងនឹងមិនទិញ ឬលក់ពត៏មានផ្ទាល់ខ្លួនរបស់អ្នកឡើយ។

## ការទទួលខុសត្រូវរបស់យើង

- យើងបានតំរូវតាមច្បាប់ ឲ្យរក្សាទុកជាសម្ងាត់ និងការធានានៃការការពារពត៌មានសុខភាពរបស់អ្នក។
- យើងនឹងឲ្យអ្នកដឹងយ៉ាងឆាប់ បើមានបទល្មើសបំពានកើតមានឡើង ដែលធ្វើឲ្យមានខូចការរក្សាទុកជាសម្ងាត់ ឬ ការធានានៃពត៌មានរបស់អ្នក។
- យើងត្រូវប្រព្រឹត្តតាមករណីយកិច្ច និងការអនុវត្តន៍ផ្ទាល់ខ្លួន ដែលបានពណ៌នានៅក្នុងសេចក្តីជូនដំណឹងនេះ និងជូន អ្នកនូវក្រដាសថតចម្លង១សន្លឹក។
- យើងនឹងមិនប្រើ ឬចែកចាយពត៌មានរបស់អ្នក ក្រៅពីដូចបានពណ៌នានៅទីនេះ លើកលែងតែអ្នកប្រាប់ឲ្យយើងប្រើ ដោយ មានក្រដាសស្នាម។ បើអ្នកប្រាប់យើង យើងអាចប្រើ, អ្នកអាចផ្លាស់ប្តូរចិត្តរបស់អ្នកនៅគ្រប់ពេល។ ឲ្យយើងដឹង ដោយ មានក្រដាសស្នាម បើអ្នកប្តូរចិត្តរបស់អ្នក។

សំរាប់ពត៌មានជាច្រើនទៀតសូមមើល: www.hhs.gov/ocr/privacy/hipaa/understanding/consumers/noticepp.html.

### ការផ្លាស់ប្តូររយះពេលនៃសេចក្តីជូនដំណឹងនេះ

យើងអាចផ្លាស់ប្តូររយះពេលនៃសេចក្តីជូនដំណឹងនេះ, ហើយការផ្លាស់ប្តូរនឹងអនុវត្តន៍ ចំពោះពត៌មានទាំងអស់ដែលយើងមាន អំពីអ្នក។ សេចក្តីជូនដំណឹងថ្មីនឹងអាចរកបាននៅពេលស្នើសុំ និងនៅក្នុងគេហទំព័រ។

ខែថ្ងៃចាប់ប្រតិបត្តិ : ខែកញ្ញា ទី២៣ ឆ្នាំ២០១៣

# ការរើសអើងជាការប្រឆាំងនឹងច្បាប់

San Joaquin County Behavioral Health Services (SJCBHS)
អនុវត្តតាមច្បាប់សិទ្ធិពលរដ្ឋនៃសហព័ន្ធដែលសមរម្យនិងមិនមានការរើសអើងលើមូលដ្ឋាន នៃពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម អាយុ ពិការភាព ឬភេទ។ SJCBHS មិនត្រូវបដិសេធ ឬរាក់ទាក់រាប់រកពួកគេផ្សេងគ្នា ដោយសារតែពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម អាយុ ពិការភាព ឬភេទនោះឡើយ។ SJCBHS ផ្តល់ :

- ជំនួយនិងសេវាកម្មនានាដោយមិនគិតឈ្នួលដល់មនុស្សទូទៅដែលគ្មានសមត្ថភាពដើម្បីនិយាយទាក់ទងដោយប្រសិទ្ធិភាពជាមួយយើង ដូចជា៖
    - អ្នកបកប្រែភាសាមនុស្សគដែលមានលក្ខណ:សម្បត្តិ
    - ពត៌មានជាលាយលក្ខណ៍អក្សរ
- សេវាកម្មផ្ទែកភាសាដោយមិនគិតឈ្នួលដល់មនុស្សទូទៅ ដែលភាសាដើមរបស់ពួកគេមិនមែនជាភាសាអង់គ្លេស ដូចជា៖
    - អ្នកបកប្រែភាសាដែលមានលក្ខណ:សម្បត្តិ
    - ពត៌មានជាលាយលក្ខណ៍អក្សរក្នុងភាសាផ្សេងៗទៀត

បើអ្នកត្រូវការសេវាកម្មទាំងនេះ ចូរទាក់ទងទៅ SJCBHS Access Managed Care លេខ (209) 468-9370.

បើអ្នកជឿថាSJCBHSមានការបរាជ័យក្នុងការផ្តល់សេវាកម្មទាំងនេះឬមានការរើសអើងនៅក្នុងរបៀបផ្សេងទៀត លើមូលដ្ឋាន នៃពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម អាយុ ពិការភាព ឬភេទ
អ្នកអាចដាក់បណ្តឹងអយុត្តិធម៌ជាមួយ៖

SJCBHS Quality Improvement (QI) Office
1212 North California Street
Stockton, CA 95202
ទូរស័ព្ទ : (209) 468-9370 ឬទូរសារ : (209) 468-8485

អ្នកអាចដាក់បណ្តឹងអយុត្តិធម៌ដោយផ្ទាល់ឬតាមការផ្ញើតាមប៉ុស្តិ៍សំបុត្រ តាមទូរសារ ឬតាមអ៊ីមែល។
បើអ្នកត្រូវការជំនួយក្នុងការដាក់បណ្តឹងអយុត្តិធម៌ QI Office គឺអាចមានពេលសំរាប់ជួយអ្នក។
អ្នកក៏អាចដាក់បណ្តឹងត្អូញត្អែរពីសិទ្ធិពលរដ្ឋជាមួយនឹង U.S. Department of Health and Human Services (ក្រសួងមនុស្សសាស្ត្រនិងសុខភាពនៃសហរដ្ឋអាមេរិក), Office for Civil Rights

ការិយាល័យសំរាប់សិទ្ធិពលរដ្ឋដាក់បណ្តឹងអេឡិកត្រូនិចតាមរយ: Office for Civil Rights Complaint Portal ដែលអាចមានតាមរយ: https://ocrportal.hhs.gov/ocr/portal/lobby.jsf, ឬតាមរយ:ប៉ុស្តិ៍សំបុត្រឬតាមទូរស័ព្ទ៖

U.S. Department of Health and Human Services
200 Independence Avenue, SW
Room 509F, HHH Building
Washington, D.C. 20201
1-800-868-1019, 800-537-7697 (TDD)

ពាក្យបណ្តឹងការត្អូញត្អែរគឺអាចមានតាមរយ: http://www.hhs.gov/ocr/office/file/index.html

| | |
|---|---|
| Español (Spanish) | ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al (209) 468-9370. |
| 繁體中文 (Chinese) | 注意：如果您使用繁體中文，您可以免費獲得語言援助服務。請致電 (209) 468-9370. |
| Tiếng Việt (Vietnamese) | CHÚ Ý: Nếu bạn nói Tiếng Việt, có các dịch vụ hỗ trợ ngôn ngữ miễn phí dành cho bạn. Gọi số (209) 468-9370. |
| Tagalog (Filipino) | PAUNAWA: Kung nagsasalita ka ng Tagalog, maaari kang gumamit ng mga serbisyo ng tulong sa wika nang walang bayad. Tumawag sa (209) 468-9370. |
| 한국어 (Korean) | 주의: 한국어를 사용하시는 경우, 언어 지원 서비스를 무료로 이용하실 수 있습니다. 전화주세요 (209) 468-9370. |
| Հայերեն (Armenian) | ՈՒՇԱԴՐՈՒԹՅՈՒՆ՝ Եթե խոսում եք հայերեն, ապա ձեզ անվճար կարող են տրամադրվել լեզվական աջակցության ծառայություններ: Զանգահարեք (209) 468-9370. |
| فارسی (Farsi) | توجه: اگر به زبان فارسی گفتگو می کنید، تسهیلات زبانی بصورت رایگان برای شما فراهم می باشد. با (209) 468-9370 تماس بگیرید. |
| Русский (Russian) | ВНИМАНИЕ: Если вы говорите на русском языке, то вам доступны бесплатные услуги перевода. Звоните (209) 468-9370. |
| 日本語 (Japanese) | 注意事項：日本語を話される場合、無料の言語支援をご利用いただけます。(209) 468-9370, お電話にてご連絡ください。 |
| العربية (Arabic) | ملحوظة إذا كنت تتحدث اذكر اللغة فإن خدمات المساعدة ةىاللغو تتو افر لك بالمجان اتصل برقم (209) 468-9370. |
| ਪੰਜਾਬੀ (Punjabi) | ਧਿਆਨ ਦਿਓ: ਜੇ ਤੁਸੀਂ ਪੰਜਾਬੀ ਬੋਲਦੇ ਹੋ, ਤਾਂ ਭਾਸ਼ਾ ਵਿੱਚ ਸਹਾਇਤਾ ਸੇਵਾ ਤੁਹਾਡੇ ਲਈ ਮੁਫਤ ਉਪਲਬਧ ਹੈ। (209) 468-9370 'ਤੇ ਕਾਲ ਕਰੋ। |
| ខ្មែរ (Cambodian/Khmer) | ប្រយ័ត្ន៖ បើសិនជាអ្នកនិយាយភាសាខ្មែរ, សេវាជំនួយផ្នែកភាសា ដោយមិនគិតឈ្នួល គឺអាចមានសំរាប់បំរើអ្នក។ ចូរទូរស័ព្ទ (209) 468-9370. |
| Hmoob (Hmong) | LUS CEEV: Yog tias koj hais lus Hmoob, cov kev pab txog lus, muaj kev pab dawb rau koj. Hu rau (209) 468-9370. |
| हिंदी Hindi | ध्यान दें: यदि आप हिंदी बोलते हैं तो आपके लिए मुफ्त में भाषा सहायता सेवाएं उपलब्ध हैं। (209) 468-9370 पर कॉल करें। |
| ภาษาไทย (Thai) | เรียน: ถ้าคุณพูดภาษาไทยคุณสามารถใช้บริการช่วยเหลือทางภาษาได้ฟรี โทร (209) 468-9370. |